Alameda County
Social Services Agency

## ការពង្រីកកម្មវិធីមេឌីខលសម្រាប់មនុស្សពេញវ័យ

## (Older Adult Medi-Cal Expansion)

ចាប់ពីថ្ងៃទី 1 ខែឧសភា ឆ្នាំ 2022 អ្នករស់នៅខោនធីអាល់ឡាមេដា Alameda County ទាំងអស់ ដែលមានអាយុ 50 ឆ្នាំឡើងទៅ ហើយបំពេញតាមលក្ខណៈវិនិច្ឆ័យស្តីពីភាពមានសិទ្ធិទទួលបានកម្មវិធី Medi-Cal ទាំងអស់ នឹងអាចទទួលបានកម្មវិធី Medi-Cal ដែលចេញថ្លៃធានារ៉ាប់រងពេញលេញ ដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍ឡើយ!





## តើអ្វីទៅជាកម្មវិធី Medi-Cal ដែលចេញថ្លៃធានារ៉ាប់រងពេញលេញ?

កម្មវិធី Medi-Cal គឺជាកម្មវិធីធានារ៉ាប់រងសុខភាពរដ្ឋ ដែលផ្តល់ជូនសេវាថែទាំសុខភាពដោយឥតគិតថ្លៃ ឬតម្លៃទាប ដល់អ្នករស់នៅរដ្ឋកាលីហ្វ័រញ៉ា California ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

កម្មវិធី Medi-Cal ដែលចេញថ្លៃធានារ៉ាប់រងពេញលេញ រួមមាន៖

- ការថែទាំសុខភាពសង្គ្រោះបន្ទាន់
- ការពិនិត្យសុខភាពធម្មតា
- សុខភាពវេជ្ជសាស្ត្រ ធ្មេញ ផ្លូវចិត្ត ផែនការគ្រួសារ និងការថែទាំភ្នែក (ភ្នែក)
- ការព្យាបាលការប្រើប្រាស់សារធាតុខុសច្បាប់
- ការចេញវេជ្ជបញ្ជា

ការធានារ៉ាប់រងបន្ថែម រួមមានការធ្វើដំណើរទៅ និងមកពីការជួបវេជ្ជបណ្ឌិត ពេទ្យធ្មេញ និងឱសថស្ថាន សម្រាប់ការទទួលយកតាមការចេញវេជ្ជបញ្ជា។ វេជ្ជបណ្ឌិតថែទាំសុខភាពបឋម ក៏អាចផ្តល់ជូនអ្នកជំនាញណែនាំបន្តផ្នែកវេជ្ជសាស្ត្រពិសេស ប្រសិនបើត្រូវការចាំបាច់។

ការចុះឈ្មោះក្នុងផែនការសុខភាពនៃកម្មវិធី Medi-Cal ផ្តល់ជូនការចូលទៅកាន់បណ្តាញវេជ្ជបណ្ឌិតដែលចេញថ្លៃលើការរៀបចំសេវាវេជ្ជសាស្ត្រ។

ស្វែងយល់បន្ថែមទៀត រួមទាំងរបៀបដាក់ពាក្យសុំ

## ខ្ញុំមានអាយុ 50 ឆ្នាំ ឬអាយុច្រើនជាងនេះ (ឬនៅខែឧសភា ឆ្នាំ 2022)។ តើខ្ញុំត្រូវការធ្វើអ្វីខ្លះ?

**ប្រសិនបើលោកអ្នកមានអាយុ 50 ឆ្នាំឡើងទៅ ហើយមានកំណត់លក្ខខណ្ឌលើការចេញថ្លៃធានារ៉ាប់រង ឬកម្មវិធី Medi-Cal សង្គ្រោះបន្ទាន់នោះ** លោកអ្នកនឹងទទួលបានកម្មវិធី Medi-Cal ដែលចេញថ្លៃធានារ៉ាប់រងពេញលេញដោយស្វ័យប្រវត្តិ Medi-Cal ចាប់ពីថ្ងៃទី 1 ខែឧសភា ឆ្នាំ 2022។

**ប្រសិនបើអ្នកមានអាយុ 50 ឆ្នាំឡើងទៅ ឬនឹងមានអាយុ 50 ឆ្នាំ នៅពេលណាមួយក្នុងខែឧសភា ឆ្នាំ 2022 ហើយមិនមានការចេញថ្លៃធានារ៉ាប់រងពីកម្មវិធី Medi-Cal តាមប្រភេទណាមួយទេ** លោកអ្នកអាចមានសិទ្ធិទទួលបានកម្មវិធី Medi-Cal ដែលចេញថ្លៃធានារ៉ាប់រងពេញលេញចាប់ពីថ្ងៃទី 1 ខែឧសភា ឆ្នាំ 2022។

**ប្រសិនបើលោកអ្នកមានអាយុក្រោម 49 ½ ឆ្នាំ គិតត្រឹមថ្ងៃទី 1 ខែមិថុនា ឆ្នាំ 2022 ឬក្រោយថ្ងៃនេះ** លោកអ្នកអាចមានសិទ្ធិទទួលបានកម្មវិធី Medi-Cal ដែលចេញថ្លៃធានារ៉ាប់រងមានកំណត់លក្ខណ្ឌ។ នៅពេលលោកអ្នកមានអាយុ 50 ឆ្នាំ លោកអ្នកនឹងចាប់ផ្តើមទទួលបានកម្មវិធី Medi-Cal ដែលចេញថ្លៃធានារ៉ាប់រងពេញលេញដោយមិនចាំបាច់ដាក់ពាក្យសុំម្តងទៀតឡើយ។

**សម្រាប់ព័ត៌មានបន្ថែម សូមមើលសំណួរដែលសួរញឹកញាប់អំពីការពង្រីកកម្មវិធីសម្រាប់មនុស្សពេញវ័យ (Older Adult Expansion) តាមវិបសាយ៖** https://www.alamedacountysocialservices.org/acssa-assets/PDF/OAE-FAQ-CAM.pdf

## របៀបដាក់ពាក្យសុំ៖

**សូមដាក់ពាក្យសុំតាមអនឡាញ**តាមវិបសាយ www.mybenefitscalwin.org.

**សូមដាក់ពាក្យសុំតាមទូរស័ព្ទលេខ (510) 272-3663.**

សូមអញ្ជើញមកដោយផ្ទាល់ ឬផ្ញើពាក្យសុំតាមប៉ុស្តប្រៃសណីយ៍មកការិយាល័យណាមួយរបស់យើង៖

**North County Self-Sufficiency Center**
2000 San Pablo Ave.
Oakland, CA 94612

**Eastmont Self-Sufficiency Center**
6955 Foothill Blvd., Suite 100
Oakland, CA 94605

**Enterprise Self-Sufficiency Center**
8477 Enterprise Way
Oakland, CA 94621

**Eden Area Multi-Service Center**
24100 Amador St.
Hayward, CA 94544

**Livermore Self-Sufficiency Center**
2499 Constitution Drive
Livermore, CA 94551

**Fremont Office**
39155 Liberty St., Suite C330
Fremont, CA 94536

**ម៉ោងធ្វើការនៅការិយាល័យ៖**
ចន្ទ ដល់ សុក្រ 8:30 ព្រឹក – 5:00 ល្ងាច
**ការរក្សាគម្លាតសង្គមសមស្រប និងការគោរពតាមការពាក់ម៉ាស់ដែលជាកាតព្វកិច្ចត្រូវអនុវត្ត។**